# របាំអប្សរា



របាំអប្សរា

រៀបរៀងដោយក្រសួងអប់រំយុវជន និងកីឡា

និងបណ្ណាល័យអង្គការសន្តិស្ម័គ្រចិត្ត (SVA)

គូររូបដោយលោក ហ៊ឹ ចិន្តា

រក្សាសិទ្ធិដោយ អង្គការសន្តិស្ម័គ្រចិត្ត (SVA)

បោះពុម្ពឆ្នាំ២០០៦

# របាំអប្សរា



បោះពុម្ពផ្សាយដោយអង្គការសន្តិស្ម័គ្រចិត្ត (SVA)

បោះពុម្ពដោយបណ្ណាល័យអង្គការ SVA

វិចិត្រូបភាពដោយ លោក ហ៊ុ ចិន្តា



សម្តេចព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមៈ នារីរ័តន៍ សិរីវឌ្ឍនា

របាំបុរាណខ្មែរ មានដើមកំណើតរាប់ពាន់ឆ្នាំមកហើយ ដូចជា របាំមណីមេខលា សុវណ្ណមច្ឆា ទេពមនោរម្យជាដើម ។ ប៉ុន្តែ របាំអប្សរា ដែលស្ថិតនៅក្នុងរបាំបុរាណដែរនោះ ទើបតែបានបង្កើតឡើង ក្នុងអំឡុងឆ្នាំ ៥០ នៃសតវត្សទី ២០ ដោយស្នាព្រះហស្តសម្តេចព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមៈ នារីរតន៍ សិរីវឌ្ឍនា ។





អប្សរាជាស្ត្រីនៅស្ថានសួគ៌ដែលមានរូបសម្បត្តិល្អស្រស់ ។ នៅស្ទើរគ្រប់ប្រាសាទ ពិសេសប្រាសាទអង្គរវត្ត គេបានឆ្លាក់រូបអប្សរាប្រមាណជាង ១ ០០០ ដែលមានការតុបតែងកាយផ្សេងៗគ្នាទាំងអស់ ។ ប៉ុន្តែតាមសៀវភៅរបស់លោកម៉ាសូម៉ូតុ អៃអ៊ិធិ មានចំណងជើងថា ម៉េហ្គុមិហ្គុនប៊ុ ថាមានរហូតដល់ជាង ២ ០០០ អប្សរា ។







នាងអប្សរាមានភារកិច្ចរាំថ្វាយអាទិទេព ដើម្បីសុំសេចក្ដីសុខសប្បាយ ដល់ប្រជារាស្ត្រ និងប្រទេសជាតិ ។





ចំលាក់រឿង " កូរសមុទ្រទឹកដោះ " នៅជញ្ជាំងប្រាសាទអង្គរវត្ត ខាងកើតឆៀងខាងត្បូង



មានរឿងនិទានថា អប្សរាកើតចេញពីការកូរសមុទ្រទឹកដោះរវាងពួកយក្ស និងទេវតាដើម្បីចំរាញ់យកទឹកអម្រឹតដែលផឹកទៅមិនស្លាប់មានជីវិតស្ថិតស្ថេរជារៀងរហូត ។ រឿងនេះមានឆ្លាក់លើជញ្ជាំងប្រាសាទនានាពិសេសនៅប្រាសាទអង្គរវត្តថែវជាន់ទីមួយ ផ្នែកខាងកើត ។ ចំលាក់រឿងនេះមានប្រវែង៤៩ម៉ែត្រកន្លះ ។ នៅខាងលើផ្ទាំងចំលាក់ទាញនាគ យើងឃើញមានលេចចេញរូបនាងអប្សរាជាច្រើន ។ ចំណែក នៅប្រាសាទបាយ័ន មុខខ្លោងទ្វារចូល មានរូបចំលាក់ជាពីរជួរដែលម្ខាងជាពួកទេវតា និងម្ខាងទៀតជាពួកយក្ខ កំពុងទាញនាគក្នុងរឿងកូរសមុទ្រទឹកដោះដែរ ។




មកុដកំពូលប្រាំ
ផ្កាមាស
រយ៉ាផ្កាម្ទេស
សុរ៉ង ក
ស្មាប់ដៃ
ខ្សែក្រវាត់ទឹមខាត់
ប្រដាប់ដៃ
សំពត់
ប្រដាប់ជើង

គំនិតនៃការបង្កើតរបាំអប្សរា គឺយកតាមលំនាំនៃចំលាក់នៅតាមប្រាសាទ ពិសេសគឺការតុបតែងកាយ ។





ភ្លេងពិណពាទ្យបន្លឺឡើង  អ្នករបាំចេញមករាំយ៉ាងទន់ភ្លន់តាមក្បាច់ផ្សេងៗដែលជាកាយវិការតំណាងពាក្យសំដី ។



## ចំរៀងរបាំអប្សរា

“ ថ្ងៃនេះប្អូនសប្បាយក្នុងចិន្តា យើញជាតិបុប្ផាដុះក្នុងសួន ។
នឹងធ្វើបូជា ច្រើនចំនួន ដាក់ជិតខាងខ្លួនទិសយនា ។
បើអ្នកពេញចិត្តចេតនា យើងនឹងអោយបុប្ផាភ្លងនេះអើយ ។”




ដកស្រង់ចេញពីសៀវភៅ **របាំខ្មែរ** របស់អ្នកនិពន្ធ **ពេជ្រ ទុំក្រវិល**

- ប្រើម្រាមចង្អុលតែមួយនេះមានន័យថា ចង្អុលបង្ហាញប្រាប់ រាយរ៉ាប់ ។
- កាយវិការជីបម្រាមទាំងប្រាំនេះ មានន័យថា ផ្កា ។





ច្រៀងបន្ត ៖

“ ដល់សួននួនល្អង នាំភីលៀង នួននាងទតសួន ជាកំសាន្ត ។
ភីលៀងបេះផ្កា ថ្វាយយោវមាល្យ កំសាន្តហឫទ័យ ក្នុងសួនច្បារ ។
បុប្ផជាតិឃ្លាតធ្លាក់ សួគ៌វិមាន ចិន្តាស្មានមេត្រី ដោយក្តីស្ម័គ្រ ។”



• កាយវិការជីបម្រាមពីរ ហើយប្រើដៃម្ខាងទៀតទ្រ នេះមានន័យថា បេះ ឬកាច់ផ្កា



• តួឯកស្លៀកពាក់សប្រើកាយវិការកាន់ផ្កា មកដាក់ជិតច្រមុះ នេះមានន័យថា ហើប ឬហិតផ្កា ។

ច្រៀងបន្ត ៖

« ក្រងពុលជាវិយោល ជរសំយុង វិជ្ជូលប្រុងក្រងជាសង្វារពាក់ ។
វ័ត្ននរីមានឆោម វិល័យលក្ខណ៍ អាចទាញទាក់ចិត្តប្រុស ផក់ជាប់អើយ ។ »





ក្រោយពីដើរកំសាន្តក្នុងសួនច្បារហើយ នាងអប្សរាបានគោរពលាដោយលើកដៃសំពះ ។ ក្នុងរបាំបុរាណខ្មែរ ការចាប់ផ្តើម និងការបញ្ចប់តែងសំដែងគារវកិច្ចដោយលើកដៃសំពះតាមលំដាប់ថ្នាក់ចំពោះអ្នកទស្សនា ។





ក្រោយពីធ្វើគារវកិច្ច ជំរាបលារួចហើយ នាងអប្សរា និងភីលៀង នាំគ្នាវិលទៅកាន់ទីស្ថានវិញ ។ នាងអប្សរាប្រើកាយវិការលើកដៃ និងជើងនេះមានន័យថា នាងត្រៀមលក្ខណៈហោះទៅកាន់ឋានសួគ៌វិញ ។ នាងអប្សរារាំពត់ពេនតាមចង្វាក់ភ្លេងរន្ទើន ក្នុងន័យបង្ហាញការហោះហើរឆ្លងកាត់ពពកដល់ទីឋានសួគ៌ដ៏សែនមនោរម្យ ។







អ្នកទស្សនាតែងនឹកគិតដល់អតីតកាលដ៏ពិសេស ស្ញើចសរសើរបុព្វបុរសខ្មែរដែលមានបញ្ញាញាណដ៏កំពូល ក្នុងការបង្កើតរបាំអប្សរាទុកអោយកូនចៅ ។ របាំអប្សរាបានឆ្លុះបញ្ចាំងអោយឃើញពីអត្តសញ្ញាណនៃព្រលឹងវប្បធម៌ខ្មែរដែលមានចរិតទន់ភ្លន់រួសរាយ តែរឹងប៉ឹងនឹងនរម៉ឹងម៉ាត់ដូច្នេះ កូនខ្មែរគួរមានមោទនៈ និងគាំទ្រថែរក្សា ៕

xxxxxxx ចប់ xxxxxxx



រូបថតដកស្រង់ចេញពីសៀវភៅ **របាំព្រះរាជទ្រព្យ**



លេខអាយ-១០: ៩៩៩៥០-៥៦-០៤-៦
ISBN-10: 99950-56-04-6
លេខអាយ-១៣: ៩៧៨-៩៩៩៥០-៥៦-០៤-៩
ISBN-13: 978-99950-56-04-9